**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

នាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

# សេចក្តីជូនព័ត៌មាន

ឯកឧត្តម **ប្រាក់ សុខុន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា នឹងដឹកនាំគណៈប្រតិភូអញ្ជើញចូលរួម «កិច្ចប្រជុំពិសេសរដ្ឋមន្ត្រីការបរទេសអាស៊ាន-សហរដ្ឋអាមេរិក» ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ០៤ ឧសភា ឆ្នាំ ២០១៧ នៅរដ្ឋធានីវ៉ាស៊ីងតោន សហរដ្ឋអាមេរិក។

នេះជាកិច្ចប្រជុំលើកទី១ រវាងរដ្ឋមន្ត្រីការបរទេសអាស៊ាន និងរដ្ឋមន្ត្រីការបរទេសអាមេរិក ចាប់តាំងពីរដ្ឋបាលថ្មីរបស់លោកប្រធានាធិបតី ដូណាល់ ត្រាំ ចូលកាន់អំណាចនៅខែ មករា ឆ្នាំ២០១៧នេះ។

មានការរំពឹងទុកថា កិច្ចប្រជុំនេះនឹងបញ្ជាក់អះអាងឡើងវិញនូវបំណងរួម និងរឹងមាំរបស់ភាគីទាំងពីរក្នុងការពង្រឹង និងធ្វើឲ្យស៊ីជម្រៅទំនាក់ទំនងដៃគូសន្ទនារវាងអាស៊ាន និងសហរដ្ឋអាមេរិក ដែលត្រូវបានថ្នាក់ដឹកនាំអាស៊ានតំឡើងមកជាដៃគូយុទ្ធសាស្ត្រ កាលពីខែវិច្ឆិកា ឆ្នាំ ២០១៥។ គួរកត់សំគាល់ផងដែរថា អាមេរិកជាដៃគូពាណិជ្ជកម្មធំបំផុតទី៤ របស់អាស៊ាន។

ក្នុងអំឡុងពេលស្នាក់នៅរដ្ឋធានីវ៉ាស៊ីងតោន ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រាក់ សុខុន ក៏នឹងមានជំនួបទ្វេភាគីជាមួយឯកឧត្តម ចន អេហ្វ ខេល្លី រដ្ឋមន្ត្រីសន្តិសុខមាតុភូមិរបស់អាមេរិក ផងដែរ។

ភ្នំពេញ, ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៧

អាសយដ្ឋាន: លេខ ៣ វិថី **សម្តេច ហ៊ុន សែន**
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh